**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ១៣ សរណន**

លេខ 5621
ថ្ងៃ 30 ខែ 10

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និងទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

នាយកដ្ឋាន.រដ្ឋបាល.

កន្លងមក រាជរដ្ឋាភិបាលបានធ្វើការតែងតាំងមន្ត្រីមួយចំនួន ជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារបស់ឧបនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយផ្តល់ជូននូវ ***«ឋានៈស្មើ» បន្ថែមលើមុខងារបច្ចុប្បន្ន*** ហើយមន្ត្រីទាំងនោះត្រូវបានរៀបចំបៀវត្សជូនតាម ***«ឋានៈស្មើ»*** ដែលមានកម្រិតខ្ពស់ជាង ***ឋានៈនៃមុខងារបច្ចុប្បន្ន*** ។

ដោយសារបច្ចុប្បន្ននេះ សភាពការណ៍សេដ្ឋកិច្ចកំពុងជួបប្រទះនឹងផលវិបាកនៃវិបត្តិសេដ្ឋកិច្ចសកល ដែលតម្រូវឱ្យរាជរដ្ឋាភិបាលមានវិធានការសន្សំសំចៃថវិកាជាតិ រាជរដ្ឋាភិបាលសូមធ្វើការណែនាំឱ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ចធ្វើការកែសម្រួលបៀវត្សរបស់មន្ត្រីខាងលើ ដូចតទៅ ៖

១- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន ***ចាប់ពីស្មើ «អនុរដ្ឋលេខាធិការ»*** ឡើងទៅ ***ហើយ បានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងឋានៈនៃមុខងារបច្ចុប្បន្ន*** គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស ***តាមឋានៈនៃមុខងារបច្ចុប្បន្ន*** របស់ខ្លួនវិញ ។

២- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន ***ទាបជាង «អនុរដ្ឋលេខាធិការ» ហើយបានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងអនុរដ្ឋលេខាធិការ*** គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស ***ត្រឹមឋានៈ អនុរដ្ឋលេខាធិការ*** ។

៣- ចំពោះមន្ត្រីដែលមានឋានៈក្នុងមុខងារបច្ចុប្បន្ន ***ទាបជាង «អនុរដ្ឋលេខាធិការ» ហើយបានទទួលការតែងតាំងក្នុង «ឋានៈស្មើ» ខ្ពស់ជាងឋានៈក្នុងមុខងារបច្ចុប្បន្ន តាមលំដាប់ថ្នាក់ រហូតដល់ឋានៈស្មើអនុរដ្ឋលេខាធិការ*** គឺត្រូវរៀបចំឱ្យទទួលប្រាក់បៀវត្ស ***តាមឋានៈដែលទទួលបានក្នុងការតែងតាំងនៃ «ឋានៈស្មើ»*** ។

ការណែនាំខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តពីខែ វិច្ឆិកា ឆ្នាំ ២០០៩ នេះតទៅ ។

ត្រូវចាត់ទុកជានិរាករណ៍នូវ ***សារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ១២ សរណន ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩*** ។

បានទទួលការណែនាំនេះហើយ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងប្រធានស្ថាប័នមានសមត្ថកិច្ចត្រូវអនុវត្ត ឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងខេត្ត-រាជធានីភ្នំពេញ*
- *ឯកសារ-កាលប្បវត្តិ*